ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

នារសៀលថ្ងៃចន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) បានទទួលជួបពិភាក្សាការងារជាមួយតំណាងសហភាពអឺរ៉ុប និងតំណាងដៃគូអឺរ៉ុបប្រចាំកម្ពុជា (ដែក, បារាំង, អាល្លឺម៉ង់, ស៊ុយអ៊ែត និងស្វីស) ដឹកនាំដោយលោក Franck Viault អគ្គទីប្រឹក្សា និងជាប្រធានទទួលបន្ទុកផ្នែកកិច្ចសហប្រតិបត្តិការនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា ។ គោលដៅចម្បងនៃជំនួបនេះ គឺដើម្បីពិភាក្សាអំពីការត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប-ដៃគូអឺរ៉ុប លើសេចក្តីព្រាងយុទ្ធសាស្ត្ររួមរបស់អឺរ៉ុបស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជា ឆ្នាំ២០២១-២០២៧ និងសេចក្តីព្រាងកម្មវិធីណែនាំពហុឆ្នាំរបស់សហភាពអឺរ៉ុប ឆ្នាំ២០២១-២០២៧ ។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ **ឈៀង យ៉ាណារ៉ា** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះតំណាងសហភាពអឺរ៉ុប និងដៃគូអឺរ៉ុបទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងជំនួបពិភាក្សាផ្ទាល់នាថ្ងៃនេះ និងបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលសម្រេចបានដ៏ល្អប្រសើរ ក្នុងការអនុវត្តយុទ្ធសាស្ត្ររួមរបស់អឺរ៉ុបស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជា ឆ្នាំ២០១៤-២០២០ និងកម្មវិធីណែនាំពហុឆ្នាំរបស់សហភាពអឺរ៉ុប ឆ្នាំ២០១៤-២០២០ ក៏ដូចជាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កន្លងមក ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ននៅកម្ពុជា ។ ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហភាពអឺរ៉ុប និងដៃគូអឺរ៉ុបទាំងអស់ដែលបានរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការឆ្លើយតបទៅនឹងការទប់ស្កាត់, ការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការកាត់បន្ថយផលប៉ះពាល់ដល់សង្គម-សេដ្ឋកិច្ចនៅប្រទេសកម្ពុជានាពេលកន្លងមក ។

**តំណាងដៃគូអឺរ៉ុប** បានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពល្អប្រសើរដែលសម្រេចបានតាមរយៈវឌ្ឍនភាពនៃវិស័យអាទិភាពចំនួន ៤ រួមមាន÷ ១) ការអភិវឌ្ឍវិស័យសង្គមកិច្ច, ២) ការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងចីរភាព, ៣) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង និងជនបទ និង ៤) អភិបាលកិច្ច និងអន្តរវិស័យ ។ សមិទ្ធផលទាំងនេះ គឺជាសក្ខីភាពនៃការប្តេជ្ញាបន្តគាំទ្ររបស់សហភាពអឺរ៉ុប និងប្រទេសជាសមាជិកសហភាពអឺរ៉ុប និងសហព័ន្ធស្វីសសម្រាប់ដំណើរការនៃកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ។ **តំណាងដៃគូអឺរ៉ុប** ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររវាងគ្រប់ដៃគូអឺរ៉ុបទាំងអស់ប្រចាំនៅកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាកន្លងមក ។ ទន្ទឹមនឹងនេះ **តំណាងដៃគូអឺរ៉ុប** ក៏បានជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** អំពីវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររួមរបស់អឺរ៉ុប ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជា ឆ្នាំ២០២១-២០២៧ និង

សេចក្ដីព្រាងកម្មវិធីណែនាំពហុឆ្នាំរបស់សហភាពអឺរ៉ុប ឆ្នាំ២០២១-២០២៧ គឺនឹងត្រូវបញ្ចប់នាចុងខែមករា ឆ្នាំ២០២១ នេះ ដើម្បីត្រៀមសម្រាប់ដាក់ពិភាក្សា និងប្រមូលធាតុចូល និងអនុសាសន៍ ក្នុងកិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប-ដៃគូអឺរ៉ុបប្រចាំកម្ពុជា ដែលគ្រោងនឹងប្រព្រឹត្តទៅក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០២១ ខាងមុខនេះ ។

ជារួម ភាគីទាំងពីរ បានឯកភាពជាគោលការណ៍លើអាទិភាពសម្រាប់យុទ្ធសាស្ត្ររួមរបស់អឺរ៉ុបស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជា ឆ្នាំ២០២១-២០២៧ ដូចមានចែងក្នុងយុទ្ធសាស្ត្រ-ចតុកោណដំណាក់កាលទី ៤ គឺ ១) ការអភិវឌ្ឍធនធានមនុស្ស, ២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ៣) ការលើកស្ទួយវិស័យឯកជន និងការងារ និង ៤) ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។ ដោយឡែក ចំពោះកម្មវិធីណែនាំពហុឆ្នាំ ២០២១-២០២៧ ដែលជាកម្មវិធីសហប្រតិបត្តិការរវាងសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា, ភាគីទាំងពីរបានឯកភាពជាគោលការណ៍លើវិស័យអាទិភាពចំនួន ៣ រួមមាន÷ ១) វិស័យសេដ្ឋកិច្ច និងការងារ, ២) វិស័យអប់រំ និងបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និង ៣) វិស័យអភិបាលកិច្ច ។

គួរបញ្ជាក់ផងដែរថា ក្នុងចន្លោះឆ្នាំ១៩៩២-២០២០ ដៃគូអឺរ៉ុប (សហភាពអឺរ៉ុប និងប្រទេសសមាជិកចំនួន ១០ ព្រមទាំងសហព័ន្ធស្វីស) បានផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុបប្រមាណ ៤ ២០០ លានដុល្លារអាមេរិក សមមូលនឹង ១៩% នៃហិរញ្ញប្បទានសរុបដែលផ្ដល់ដោយដៃគូអភិវឌ្ឍន៍ទាំងអស់បានផ្ដល់ដល់កម្ពុជា ៕

❋❋❋❋❋